បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
ថ្ងៃទី០៧ ខែ... ឆ្នាំ២០២១
ក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូង ខេត្តសៀមរាប**

[redacted]

សំណុំរឿងព្រហ្មទណ្ឌលេខ ១៥០៩
ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០
សំណុំរឿងស៊ើបសួរលេខ ១២៧៤
ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០
សំណុំរឿងជំនុំជម្រះលេខ ៥៣
ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១
**សាលក្រមលេខ ៣៩ "ច"/២៧៣**
ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈជំនុំជម្រះ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ វេលារសៀល និងប្រកាសសាលក្រម នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ វេលារសៀល នៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តសៀមរាប ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ឋានៈ ចៅក្រម

**តំណាងអយ្យការ**

លោក [redacted] ឋានៈ ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ឋានៈ ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១៥០៩ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] ណូ ហៅ គឿ ភេទប្រុស កើតថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៧ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិជំ [redacted] ខេត្តសៀមរាប មុខរបរ គ្មានកម្រិតវប្បធម៌ថ្នាក់ទី០៦ នៅលីវ ឪពុកឈ្មោះ [redacted] អាន "រស់" ម្តាយឈ្មោះ [redacted] ហ៊ី "រស់" ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៦៤ ឃខ/ធ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

២.ឈ្មោះ [redacted] រ៉ាន់ ភេទប្រុស កើតឆ្នាំ២០០០ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិវត្ត [redacted] ខេត្តសៀមរាប មុខរបរនេសាទ កម្រិតវប្បធម៌ថ្នាក់ទី០២ នៅលីវ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] នួន "រស់" ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៦៥ ឃខ/ធ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិមុខវែង ឃុំខ្នារពោធិ៍ ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី ៣ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣.ឈ្មោះ [redacted] ប៊ុនធឿន ហៅ តាក់ ភេទប្រុស កើតឆ្នាំ១៩៩២ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅ[redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ[redacted] ខេត្តសៀមរាប មុខរបរកម្មករសំណង់ កម្រិតវប្បធម៌ថ្នាក់ទី០៦ ប្រពន្ធឈ្មោះ [redacted] ស្រីមុំ មានកូន ០១ នាក់ ឪពុកឈ្មោះ [redacted] ប៊ុន "រស់" ម្តាយឈ្មោះ [redacted] សុខា "រស់" ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៦៦ យឧ/ធ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ករណីមិនរាងចាល) ប្រព្រឹត្តនៅភូមិមុខប៉ែន ឃុំមុខប៉ែន ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៣ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ ។

## អង្គហេតុនៃរឿងមានដូចតទៅៈ

កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ស្ថិតនៅភូមិមុខប៉ែន ឃុំមុខប៉ែន ស្រុកពួក ខេត្តសៀមរាប កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថស្រុកពួក ដឹកនាំដោយលោក [redacted] ស៊ីណា បានចុះបង្ក្រាបករណីគ្រឿងញៀន ឃាត់ខ្លួនបានឈ្មោះ [redacted] ណូ ហៅ គឿ ដកហូតគ្រឿងញៀនចំនួន ០៦ កញ្ចប់ ដែលឈ្មោះ [redacted] ណូ បានកាន់ជាប់នៅនឹងដៃ ។ ក្រោយពីឃាត់ខ្លួន [redacted] ណូ បានសហការណ៍រហូតបន្តឃាត់បានបក្ខពួកចំនួន ០២ នាក់ទៀត មានឈ្មោះ [redacted] វ៉ាន់ និងឈ្មោះ [redacted] ប៊ុនធឿន ហៅ តាក់ ដែលជាអ្នកធ្លាប់លក់គ្រឿងញៀនឱ្យឈ្មោះ [redacted] ណូ ។ ក្រោយពីឃាត់ខ្លួនក៏បន្តធ្វើតេស្តរកសារធាតុញៀនជាលទ្ធផល វិជ្ជមាន ។

បានឃើញ របាយការណ៍សរុបលេខ ២៨៧/២០ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធខេត្តសៀមរាប ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៦៦ អ.យ/២១ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តសៀមរាប ។

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៥៤ ពស.ព្រស/ធ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប ។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ២៥៤ ពស.ព្រជ (ក) ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ណូ ហៅ គឿ បានឆ្លើយថា សមត្ថកិច្ចឃាត់ខ្លួនពេលកំពុងប្រើប្រាស់ថ្នាំញៀន និងបានដកហូតថ្នាំញៀនចំនួន ០៦ (ប្រាំមួយ)កញ្ចប់ ។ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ [redacted] វ៉ាន់ និងឈ្មោះ [redacted] ប៊ុនធឿន បានចំនួន ៦ (ប្រាំមួយ)កញ្ចប់ តម្លៃ ១៥០,០០០ (ដប់ប្រាំម៉ឺន)រៀល ។ បន្ទាប់ពីខ្លួនបានទទួលថ្នាំញៀនពីឈ្មោះ [redacted] វ៉ាន់ និងឈ្មោះ [redacted] ប៊ុនធឿន រួចក៏ត្រូវសមត្ថកិច្ចមកឃាត់ខ្លួនតែម្តង ។

-ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ បានឆ្លើយថា កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ខ្លួនបានជូនឈ្មោះ [redacted] ប៊ុនធឿន ទៅរង្វង់មូលគ្រុឌ ពេលទៅដល់ឈ្មោះ [redacted] ប៊ុនធឿន បានចុះទៅយកកញ្ចប់ថ្នាំញៀនដែលគេប្លុងចោល បន្ទាប់មកក៏យកទៅឲ្យឈ្មោះ [redacted] ណូ ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង ។ ថ្នាំញៀនខ្លួនទិញពីមនុស្សពុំស្គាល់តាមទូរស័ព្ទ ដោយគេយកទៅប្លុងចោលឲ្យខ្លួនទៅយក ។

-ជនជាប់ចោទឈ្មោះ [redacted]ប៊ុនធឿន ហៅ តាក់ បានឆ្លើយថា កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ខ្លួនជិះម៉ូតូចេញពីផ្ទះជាមួយឈ្មោះ [redacted]វ៉ាន់ ដើម្បីទៅយកថ្នាំញៀនគេប្លង់ចោលនៅរង្វង់មូលគ្រុឌ ពេលបានថ្នាំញៀនយកទៅឲ្យឈ្មោះ [redacted] ណូ ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ ថ្នាំញៀននេះទិញពីមនុស្សពុំស្គាល់តាមទូរស័ព្ទ ដោយគេប្លង់ចោលឲ្យខ្លួនទៅយក ។

-តាមកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ របស់ការិយាល័យបទល្មើសគ្រឿងញៀន ថា បានចាប់យកវត្ថុតាងពីឈ្មោះ [redacted] ណូ ហៅ តឿ មានម្សៅគ្រីមពណ៌សថ្លាចំនួន ០៦ (ប្រាំមួយ) កញ្ចប់ ទម្ងន់ ០.៧៩ (សូន្យចុចចិតសិបប្រាំបួន) ក្រាម, ទូរស័ព្ទដៃម៉ាក Nokia ចុចពិល ពណ៌ខ្មៅ ០១ គ្រឿង និងឧបករណ៍ប្រើប្រាស់ថ្នាំញៀនមួយចំនួន , បានចាប់យកវត្ថុតាងពីឈ្មោះ [redacted] ប៊ុនធឿន ហៅ តាក់ មានទូរស័ព្ទដៃម៉ាក Samsung ពណ៌មាស ០១ គ្រឿង ។

-តាមកំណត់ហេតុទទួលស្គាល់វត្ថុតាងចាប់យក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ របស់ការិយាល័យបទល្មើសគ្រឿងញៀន ឈ្មោះ [redacted]ណូ ហៅ តឿ និងឈ្មោះ ឈ្មោះ[redacted] ប៊ុនធឿន ហៅ តាក់ បានទទួលស្គាល់វត្ថុចាប់យករបស់ខ្លួន ដូចមានក្នុងកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ។

-តាមកំណត់ហេតុវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ របស់ការិយាល័យបទល្មើសគ្រឿងញៀន បានវេចខ្ចប់វត្ថុតាងរបស់ឈ្មោះ [redacted] ណូ ហៅ តឿ និងឈ្មោះ [redacted] ប៊ុនធឿន ហៅ តាក់ ដាក់ក្នុងស្រោមសំបុត្រពណ៌សលេខ ០០២៧៧ ។

-តាមកំណត់ហេតុធ្វើតេស្តទឹកនោមរកជាតិញៀនលើជនសង្ស័យ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ របស់ការិយាល័យបទល្មើសគ្រឿងញៀន លើជនជាប់ចោទឈ្មោះ [redacted] ណូ ហៅ តឿ, ឈ្មោះ[redacted]វ៉ាន់ និងឈ្មោះ [redacted]ប៊ុនធឿន ហៅ តាក់ រកឃើញសារធាតុញៀន (វិជ្ជមាន) ។

-តាមរបាយការណ៍សរុប ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងគ្រឿងញៀន ថា នៅវេលាម៉ោង ០១ និង ០០ នាទី ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ដឹកនាំដោយលោក វរសេនីយ៍ត្រី [redacted]ស៊ី ណា មេបញ្ជាការ មូលដ្ឋានកងរាជអាវុធហត្ថ ស្រុកពួក ដោយក្តាប់បានព័ត៌មានពីមុខសញ្ញាជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមសេចក្តីរាយការណ៍ពីប្រជាពលរដ្ឋ កម្លាំងយើងបានប្រតិបត្តិការបង្ក្រាបដេញប្រដាប់ចាប់ប្រកីង ឃាត់ខ្លួនជនសង្ស័យដំបូង បានចំនួន ០១ នាក់ ឈ្មោះ [redacted]ណូ ហៅ តឿ ភេទប្រុស អាយុ ២៣ឆ្នាំ ដកហូតបានថ្នាំញៀនម្សៅគ្រីមពណ៌សថ្លាចំនួន ០៦ កញ្ចប់ ដែលរូបគេកាន់នៅនឹងដៃខាងស្តាំ និងឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន ។ ភ្លាមៗនោះឈ្មោះ [redacted] ណូ ហៅ តឿ បានសហការជាមួយកម្លាំងយើងដើម្បីបន្តឃាត់ខ្លួនបក្ខពួក ០២ នាក់ទៀត ដែលជាអ្នកលក់គ្រឿងញៀនឱ្យរូបគេ ដោយដេញប្រដាប់ចាប់ប្រកីង ឃាត់ខ្លួនជនសង្ស័យបានឈ្មោះ[redacted]វ៉ាន់ ភេទប្រុស អាយុ ២០ឆ្នាំ និងឈ្មោះ [redacted] ប៊ុនធឿន ហៅ តាក់ ភេទប្រុស អាយុ ២៨ឆ្នាំ ដែលរូបគេទាំងពីរនាក់គឺ ជាអ្នកយកថ្នាំញៀនទៅលក់ឱ្យឈ្មោះ [redacted] ណូ ហៅ តឿ ចំនួន ០៦ កញ្ចប់ ។ ហើយសមត្ថកិច្ចយើងបានធ្វើតេស្តទឹកនោមជនសង្ស័យ ឃើញមានសារធាតុញៀន (វិជ្ជមាន) ក្រោយពេលបញ្ចប់ប្រតិបត្តិការបាននាំជនសង្ស័យមកការិយាល័យជំនាញ ដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធី ។

-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣០២៣៣/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនសន្និដ្ឋានថា ថ្នាំញៀនរបស់ឈ្មោះ អ៊ុន ណូ និងឈ្មោះ [redacted] ប៊ុនធឿន មានឈ្មោះ មេតំហ្វេតាមីន (Metamfetamine) ដែលមានកម្រិតភាពសុទ្ធ ៦២.៥៥% (ហុកសិបពីរចុចហាសិបប្រាំភាគរយ) នៃទម្ងន់សរុប វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមាន ចែងលម្អិតក្នុងតារាងឧបសម្ព័នច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានបញ្ចប់ការសួរដេញដោល ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ណូ ហៅ តឿ , ឈ្មោះ [redacted] វ៉ាន់ និងឈ្មោះ [redacted] ប៊ុនធឿន ហៅ តាក់ ពិតជាបានធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន បើផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទទាំងបីនាក់មានភាពស៊ីសង្វាក់គ្នាជាមួយឯកសារផ្សេងៗក្នុងសំណុំរឿង ដូចនេះ តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរ លេខ ៦៦ អ.យ/២១ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ទុកជាបានការដដែល ។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវី

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ និងឈ្មោះ [redacted] ប៊ុនធឿន ហៅ តាក់ បានធ្វើសេចក្តីសន្និដ្ឋានថា ពេលឃាត់ខ្លួនជនជាប់ចោទទាំងពីរនាក់ គឺពុំបានដកហូតថ្នាំញៀនឡើយ ដូចនេះ ការចោទប្រកាន់ជនជាប់ចោទទាំងពីរនាក់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ពុំត្រឹមត្រូវឡើយ ។ម្យ៉ាងទៀតផ្អែកតាមចម្លើយជនជាប់ចោទទាំងពីរនាក់ថា ពួកខ្លួនចូលប្រាក់គ្នាទៅទិញថ្នាំញៀនយកមកប្រើប្រាស់តែពុំទាន់បានប្រើប្រាស់ផងត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ដូចនេះ ស្នើសុំតុលាការពិចារណាប្តូរបទចោទលើជនជាប់ចោទទាំងពីរនាក់ពីបទ ជួញដូរដោយខុសច្បាប់នូវសារ ធាតុញៀន មកបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងសុំតុលាការជួយបន្ធូរ បន្ថយទោសឲ្យបានច្រើនបំផុត ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ណូ ហៅ តឿ, ឈ្មោះ [redacted] វ៉ាន់ និងឈ្មោះ [redacted] ប៊ុន ធឿន ហៅ តាក់ បានសំណូមពរមកតុលាការថា សុំតុលាការជួយបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើភស្តុតាងឯកសារផ្សេងៗក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] ណូ ហៅ តឿ , [redacted] វ៉ាន់ , [redacted] ប៊ុនធឿន ពិតជាបានធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ស្ថិតនៅភូមិមុខប៉ែន ឃុំមុខប៉ែន ស្រុកពួក ខេត្តសៀមរាប ។ កម្លាំងសមត្ថកិច្ចឃាត់ខ្លួនបានឈ្មោះ [redacted] ណូ ហៅ តឿ ដកហូតគ្រឿងញៀន ចំនួន ០៦ កញ្ចប់ និងបន្តទៅឃាត់ខ្លួនឈ្មោះ [redacted] វ៉ាន់ និងឈ្មោះ [redacted] ប៊ុនធឿន ហៅ តាក់ ដែលជាអ្នកលក់ថ្នាំញៀនឱ្យឈ្មោះ [redacted] ណូ ។

២.ជនជាប់ចោទឈ្មោះ [redacted] ណូ ហៅ តឿ បានឆ្លើយទទួលស្គាល់ថ្នាំញៀនចំនួន ០៦ (ប្រាំមួយ) កញ្ចប់ ទិញពីឈ្មោះ [redacted] វ៉ាន់ និងឈ្មោះ [redacted] ប៊ុនធឿន តម្លៃ ១៥០,០០០ (ដប់ប្រាំម៉ឺន) រៀល ។ចម្លើយទទួលស្គាល់របស់ជនជាប់ចោទរូបអាចឲ្យតុលាការជឿនបាន ដោយស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ និងឈ្មោះ [redacted] ប៊ុនធឿន ថា កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ពួកខ្លួនបានជិះម៉ូតូទៅយកថ្នាំញៀនដែលគេប្លុងចោលនៅរង្វង់មូលគ្រុឌ បន្ទាប់មកក៏យកទៅលក់ឲ្យឈ្មោះ [redacted] ណូ ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ ចម្លើយរបស់ជនជាប់ចោទទាំងបីនាក់នេះ ក៏មានភាពស៊ីសង្វាក់ទៅនឹងភស្តុតាង

កំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ , កំណត់ហេតុទទួលស្គាល់វត្ថុតាងចាប់យក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ និងកំណត់ហេតុធ្វើតេស្តទឹកនោមរកជាតិញៀនលើជនសង្ស័យ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ រកឃើញសារធាតុញៀន (វិជ្ជមាន) ។

៣.ផ្អែកតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ថា ខ្លួនធ្លាប់ជាប់ពន្ធនាគាររយៈពេល ០២ឆ្នាំ ពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ហើយក្រោយពីខ្លួនចេញពីពន្ធនាគារក៏ចាប់ផ្តើមប្រើប្រាស់ និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀនម្តងទៀត ។ ដែលអំពើរបស់ជនជាប់ចោទរូបនេះ គឺជាករណីមិនរាងចាល ស្របតាមបញ្ញត្តិមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ ដែលអាចឲ្យតុលាការពិចារណាផ្តន្ទាទោសជនជាប់ចោទកំរិតអតិបរមា ។

៤.ម្សៅក្រាមពណ៌សថ្លាដែលដកហូតពីជនជាប់ចោទឈ្មោះ [redacted] ណូ ហៅ តឿ មានទម្ងន់ ០,៧៦ ក្រាម មានកម្រិតភាពសុទ្ធ ៦២,៥៥% នៃទម្ងន់សរុប ឃើញថាថ្នាំញៀននេះមានបរិមាណសុទ្ធ (០,៧៦x ៦២,៥៥)១០០ = ០,៤៧ ដែលចំនួននេះតិចជាង ១៥ក្រាម ជាបទមជ្ឈិម ។

៥.ជនជាប់ចោទឈ្មោះ [redacted] ណូ ហៅ តឿ , [redacted] វ៉ាន់ , សួន ប៊ុនធឿន ជានីតិជន ដែលមានការយល់ដឹងគ្រប់គ្រាន់ចំពោះសកម្មភាពប្រព្រឹត្តរបស់ខ្លួន ហេតុនេះជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ។

៦.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ណូ ហៅ តឿ , [redacted] វ៉ាន់ , [redacted] ប៊ុនធឿន បានធ្វើឲ្យប៉ះពាល់ដល់សុខុមាលភាព សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសុវត្ថិភាពសង្គម ។

៧.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ។

៨.សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ណូ ហៅ តឿ , [redacted] វ៉ាន់ បានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងឈ្មោះ [redacted] ប៊ុនធឿន ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនករណីមិនរាងចាល ដែលច្បាប់បញ្ញត្តិថា ជាបទល្មើស និងត្រូវផ្តន្ទាទោស ។

៩.មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ណូ ហៅ តឿ , [redacted] វ៉ាន់ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិមុខប៉ែន ឃុំមុខប៉ែន ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី ៣ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១០.មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ប៊ុនធឿន ហៅ តាក់ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ករណីមិនរាងចាល) ប្រព្រឹត្តនៅភូមិមុខប៉ែន ឃុំមុខប៉ែន ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី ៣ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ។

១១.វត្ថុចាប់យកដូចមានក្នុងដីកាបង្គាប់ឲ្យតម្កល់វត្ថុតាងលេខ ៥៩៨ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ និងកំណត់ហេតុស្តីពីការបើកបិទកញ្ចប់ ថ្លឹង និងដកហូតសំណាកវត្ថុតាងដែលសង្ស័យថាជាថ្នាំញៀន ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ មាន៖

-ម្សៅគ្រីមពណ៌សថ្លាចំនួន ០៦ (ប្រាំមួយ)កញ្ចប់ ទម្ងន់ ០,៧៦ (សូន្យក្បៀសចិតសិបប្រាំមួយ) ក្រាម ។

-ទូរស័ព្ទដៃម៉ាក Samsung ពណ៌មាសចំនួន ០១ គ្រឿង

-ទូរស័ព្ទដៃម៉ាក Nokia ពណ៌ខ្មៅ ចុចពិល ចំនួន ០១ គ្រឿង

-ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន ។

Scanned with CamScanner

## ហេតុដូច្នេះ សម្រេច

**១.ផ្តន្ទាទោស៖**

ក.ឈ្មោះ [redacted] ណូ ហៅ តឿ ភេទប្រុស កើតថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៧ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ២ (ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន)រៀល។

ខ.ឈ្មោះ [redacted]វ៉ាន់ ភេទប្រុស កើតឆ្នាំ២០០០ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន)រៀល ។

ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិមុខប៉ែន ឃុំមុខប៉ែន ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី ៣ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

គ.ឈ្មោះ [redacted] ប៊ុនធឿន ហៅ តាក់ ភេទប្រុស កើតឆ្នាំ១៩៩២ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៤ (បួន)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន)រៀល ។

ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ករណីមិនរាងចាល) ប្រព្រឹត្តនៅភូមិមុខប៉ែន ឃុំមុខប៉ែន ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ ថាខណ្ឌ៣ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៨៨ នៃក្រមព្រហ្មទណ្ឌ ។

**២.**រឹបអូសវត្ថុចាប់យកតាមមាត្រា៩៣ និងមាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាន៖

ក.ម្សៅគ្រីមពណ៌សថ្លាចំនួន ០៦ (ប្រាំមួយ)កញ្ចប់ ទម្ងន់ ០,៧៦ (សូន្យក្បៀសចិតសិបប្រាំមួយ) ក្រាម ។

ខ.ទូរស័ព្ទដៃម៉ាក Samsung ពណ៌មាសចំនួន ០១ គ្រឿង

គ.ទូរស័ព្ទដៃម៉ាក Nokia ពណ៌ខ្មៅ ចុចពិល ចំនួន ០១ គ្រឿង

ឃ.ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា**[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ៩រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
សៀមរាប ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]

**ក្រឡាបញ្ជី**
[redacted]